**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៣ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើស្រល់ និង តាត្រាវ

## នៅក្នុងខេត្តកំពង់ធំ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានឃើញ ប្រកាសលេខ ៥០៩ ប្រក.កសក-ប្រ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

## ស ម្រេ ច

ប្រការ១ : បង្កើតតំបន់ប្រភពគ្រាប់ពូជឈើស្រល់ (*Pinus merkusii* Jungh. et de Vries) និងតាត្រាវ(*Fagraea fragrans* Roxb) មួយ(០១)កន្លែងដែលមានផ្ទៃដីទំហំមួយរយបួន(១០៤) ហិកតា ស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម ក្នុងភូមិសាស្ត្រឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានព្រំប្រទល់ ដូចមានកំណត់ក្នុងផែនទីមាត្រដ្ឋាន ១ ៖ ៥០ ០០០ ភ្ជាប់ជាឧបសម្ព័ន្ធ និង មាននិយាមកា: ក (០៥ ៣១ ៦០១; ១៤ ០៩ ៩២៣), ខ (០៥ ៣១ ៣៦៨; ១៤ ០៩ ៧៥៥), គ (០៥ ៣០ ៣៨២; ១៤ ០៩ ៧៥០), ឃ (០៥ ៣០ ; ២៧៥; ១៤ ០៩ ៩៨៦), ង (០៥ ៣០ ២៨៣; ១៤ ១០ ៣៦៣), ច (០៥ ៣១ ០៤៣; ១៤ ១០ ៧២១) និង ឆ (០៥ ៣១ ៣២៥;១៤ ១០ ៧៤៥) ជាខ្សែព្រំប្រទល់បិទ។ ការបង្កើតតំបន់ប្រភពគ្រាប់ពូជឈើនេះ ក្នុងគោលបំណងអភិរក្ស និង ធ្វើការសិក្សាលើលក្ខណៈសេនេទិក និង ប្រមូលគ្រាប់ពូជសម្រាប់ផ្គត់ផ្គង់ដល់តម្រូវការនៃកម្មវិធីដាំដើមឈើ និង ស្តារព្រៃឈើឡើងវិញ ។

ប្រការ២ : តំបន់ប្រភពគ្រាប់ពូជឈើនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលព្រៃឈើ ដោយមានភារកិច្ចទទួលខុសត្រូវដូចតទៅ :

- រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលមានភារកិច្ចសម្របសម្រួល សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និង បណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រង ថែរក្សា និង ប្រមូលគ្រាប់ពូជឈើ ស្រល់ និង តាត្រាវក្នុងតំបន់នេះ
- ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ (ផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម) មានភារកិច្ចគ្រប់គ្រងថែរក្សា និង ប្រមូលគ្រាប់ពូជ ព្រមទាំងការពារបង្ការភ្លើងព្រៃ និង ចាត់វិធានការទប់ស្កាត់គ្រប់រូបភាពអនាធិបតេយ្យក្នុងតំបន់ប្រភពគ្រាប់ពូជឈើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

ប្រការ៣ : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ១០ ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ធំ
- ដូចប្រការ ៤
- ឯកសារ - កាលប្បវត្តិ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

